01336646
Declassified to Public
24 September 2021

លេខ៖ D276/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 12 / 10 / 2016
ម៉ោង (Time/Heure): 15:05
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SAMAN RADA

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦**

ភាសា ៖ **ខ្មែរ/អង់គ្លេស [អង់គ្លេស ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

# ដីកាសម្រេចលើសំណើទីប្រាំមួយរបស់ អោ អាន សុំឲ្យបំពេញកិច្ចស៊ើបសួរ

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**

មុំ លុច
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តី យឹម ទិត្យ**

សូ មូស្សេនី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉ែន ពៅ

Linda BEHNKE
Laure DESFORGES NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

## I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។

២. នៅថ្ងៃទី២៧ ខែ មីនា ឆ្នាំ ២០១៥ អតីតសហចៅក្រមកាន់តំណែងខ្ញុំ បានជូនដំណឹង អោ អាន អំពីដីកាសម្រេចដាក់គាត់ឱ្យស្ថិតក្រោមការពិនិត្យពីបទប្រព្រឹត្តឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខទួលបេង ទីតាំងសម្លាប់មនុស្សគោកព្រីង និងមន្ទីរសន្តិសុខវត្តអូរត្រកួន[1]។

៣. នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ មេធាវីការពារក្តី អោ អាន ("មេធាវីការពារក្តី") បានដាក់ *សំណើទីប្រាំមួយសុំឱ្យបំពេញកិច្ចស៊ើបសួរ* ("សំណើ")[2]។

៤. នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ ខ្ញុំបានដាក់ អោ អាន ឱ្យស្ថិតក្រោមការពិនិត្យពីបទប្រព្រឹត្តឧក្រិដ្ឋកម្មថែមទៀតនៅការដ្ឋានពលកម្មដោយបង្ខំអន្លង់ជ្រៃ មន្ទីរសន្តិសុខមិត្តសុប(គរ) វត្តអង្គញជី មន្ទីរសន្តិសុខវត្តបាធាយ មន្ទីរសន្តិសុខវត្តភ្នំប្រុស វត្តតាមះ មន្ទីរសន្តិសុខចម្ការស្វាយចន្ទី មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក និងមន្ទីរសន្តិសុខវត្តស្រង៉ែ។ ខ្ញុំក៏បានដាក់ អោ អាន ឱ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋអាពាហ៍ពិពាហ៍ដោយបង្ខំនៅស្រុកកំពង់សៀម និងស្រុកព្រៃឈរ និងពីបទអំពើប្រល័យពូជសាសន៍មកលើជនជាតិចាមនៅខេត្តកំពង់ចាម។ ខ្ញុំបានដាក់ អោ អាន ឱ្យស្ថិតក្រោមការពិនិត្យដោយសារតំណែងពីមុនគាត់ជាអនុលេខាភូមិភាគកណ្តាល(ឧត្តរចាស់) ជាសមាជិកនៃគណៈភូមិភាគកណ្តាល(ឧត្តរចាស់) និងជាលេខាតំបន់ ៤១ នៅភូមិភាគកណ្តាល(ឧត្តរចាស់)[3]។

៥. នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ នៅក្នុង*សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ* ខ្ញុំបានជូនដំណឹងភាគីទាំងអស់ថា ខ្ញុំនឹងមិនស៊ើបអង្កេត

[1]សំណុំរឿង០០៤ ឯកសារ D242 *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ អោ អាន* ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥។

[2]សំណុំរឿង ០០៤ ឯកសារ D276 *សំណើទីប្រាំមួយសុំឱ្យបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ("សំណើ")។

[3]សំណុំរឿង ០០៤ ឯកសារD303 *កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀតរបស់ អោ អាន* ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦។

ថែមទៀតលើការចោទប្រកាន់ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនៅតំបន់ ៤២ និងតំបន់ ៤៣ ឡើយ ប៉ុន្តែ អាចបើកកិច្ចស៊ើបសួរឡើងវិញប្រសិនបើកាលៈទេសៈតម្រូវឲ្យធ្វើដូច្នេះ[4]។

## II. សារណា

៦. នៅក្នុងសំណើ មេធាវីការពារក្តី ស្នើសុំឲ្យស៊ើបអង្កេតបន្ថែមទៀតលើរចនាសម្ព័ន្ធបញ្ជាការ និងអំណាចធ្វើសេចក្តីសម្រេចជាក់ស្តែងរបស់បុគ្គលនានានៅភូមិភាគកណ្តាល និងនៅតំបន់ ៤១, ៤២ និង ៤៣។

៧. មេធាវីការពារក្តី អះអាងថា ការចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ៣ ("ដីកាសន្និដ្ឋានទី ៣") គឺផ្អែកលើរចនាសម្ព័ន្ធបញ្ជាការស្របច្បាប់ ដែលបានកំណត់នៅក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ("លក្ខន្តិកៈ ប.ក.ក") និងរដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ("រដ្ឋធម្មនុញ្ញ")[5]។ ផ្ទុយមកវិញ មេធាវីការពារក្តី អះអាងថា មានរចនាសម្ព័ន្ធបញ្ជាការមិនផ្លូវការ ហើយអំណាចភាគច្រើនកាន់កាប់ដោយសាច់ញាតិរបស់ តា ម៉ុក និង កែ ពក គឺជាសាច់ញាតិដែលមានសិទ្ធិអំណាចលើបញ្ហាសំខាន់ៗ ដូចជា សន្តិសុខ[6]។

៨. សំណើបែងចែកជាសំណើតូចៗចំនួនបី ដែលសំណើតូចៗនីមួយៗទាក់ទងនឹងតំបន់ណាមួយនៅក្នុងភូមិភាគកណ្តាល។ ផ្នែកទី ១ នៃសំណើ គឺទាក់ទងនឹងរចនាសម្ព័ន្ធធ្វើសេចក្តីសម្រេចជាក់ស្តែង និងខ្សែរយៈបញ្ជាការនៅតំបន់ ៤១[7]។ ជាពិសេស មេធាវីការពារក្តី ស្នើថា ស.ច.ស គួរ៖

ក) ស៊ើបសួរថាតើ អ៊ុំ ស៊ឹម នៅរស់ ឬស្លាប់ ហើយបើនៅរស់ ស្តាប់ចម្លើយគាត់ទាក់ទងនឹងប្រធានបទជាក់លាក់មួយចំនួន។

---

[4]សំណុំរឿង០០៤ ឯកសារ D307/3 *សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ* ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ កថាខណ្ឌ ១៣-១៤។

[5]សំណើ កថាខណ្ឌ ១០-១១។

[6]ដូចជើងទំព័រខាងលើ កថាខណ្ឌ ១១, ១៥ និង ២១។

[7]ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៣-២៧។

ខ) កំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយសាក្សី ដូចជា គូ សេម ទាក់ទងនឹងសិទ្ធិអំណាច និងអំណាចធ្វើសេចក្តីសម្រេចជាក់ស្តែងរបស់ អ៊ុំ ស៊ីម នៅតំបន់ ៤១ ទំនាក់ទំនងរបស់ អ៊ុំ ស៊ីម ជាមួយ កែ ពក និងថាតើគាត់បានបន្តធ្វើរបាយការណ៍ទៅ តា ម៉ុក ទទួលបញ្ជាពី តា ម៉ុក ឬរក្សាទំនាក់ទំនងជាមួយតា ម៉ុក ក្រោយពេលគាត់ត្រូវបានបញ្ជូនទៅភូមិភាគកណ្តាលដែរឬអត់។

គ) ស្តាប់ចម្លើយ គូ សេម ឡើងវិញ ដើម្បីផ្តល់ព័ត៌មានអំពីប្រធានបទជាក់លាក់មួយចំនួន។

ឃ) ដាក់ចូលក្នុងសំណុំរឿងនូវរូបថតរបស់ អ៊ុំ ស៊ីម ដែល គូ សេម ឬមជ្ឈមណ្ឌលឯកសារកម្ពុជា អាចមាន។

ង) កំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយសមាជិកគ្រួសាររបស់ គូ សេម និង អ៊ុំ ស៊ីម រួមមាន តា សន, យាយ ម៉ែន, អ៊ុំ ថន(ប), អ៊ុំ ថន(ស), អ៊ុំ ធុន, អ៊ុំ ឃឿង, តា សឿ, គូ ស៊ឹម, គូ រ៉ុា, និង គូ ស៊ុន។

ច) កំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយប្រតិបត្តិករទូរលេខ និងនិរសាររួមមាន សួន កានិល, លឹម សេង និង ប៊ុន អុល។

ឆ) កំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយសមាជិកគ្រួសារទាំងអស់របស់ កែ ពក និងតា ម៉ុក ដែលមានតំណែងផ្លូវការ ឬមិនផ្លូវការនៅតំបន់ ៤១[8]។

៩. ផ្នែកទី ២ នៃសំណើ ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធធ្វើសេចក្តីសម្រេច និងខ្សែរយៈបញ្ជាការជាក់ស្តែងនៅតំបន់ ៤២ ជាពិសេសសិទ្ធិអំណាចរបស់ អឿន និង ស៊ូ សឿន នៅក្នុងតំបន់នេះ[9]។ នៅខាងក្រោមនេះ មេធាវីការពារក្តី ស្នើថា ស.ច.ស គួរ៖

ក) ស្តាប់ចម្លើយឡើងវិញចំពោះឈ្មោះ ទេព ប៊ូច, បាន សៀក និង ស៊ូ សឿន។

ខ) ស្តាប់ចម្លើយ ហង្ស គឹមយេន

---

[8]ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៦។

[9]ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៨-៣២។

01336650



គ) កំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយប្រតិបត្តិការទូរលេខ និងនិរសារនៅតំបន់ ៤២

ឃ) ស្វែងរក និងស្តាប់ចម្លើយឈ្មោះ ហាប់ និង ជួន

ង) កំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយសមាជិកគ្រួសារទាំងអស់របស់ កែ ពក និង តា ម៉ុក ដែលមានតំណែងផ្លូវការ ឬមិនផ្លូវការនៅតំបន់ ៤២[10]។

១០. ផ្នែកទី៣ នៃសំណើ ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធធ្វើសេចក្តីសម្រេច និងខ្សែរយៈបញ្ជាការជាក់ស្តែងនៅតំបន់ ៤៣[11]។ មេធាវីការពារក្តី ស្នើថា ស.ច.ស គួរ៖

ក) កំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយសាក្សីនានា រួមមាន ចាន់ សាង និង លឹម សេង ទាក់ទងនឹងការប្រាស្រ័យទាក់ទងគ្នារវាង អ៊ុំ ស៊ីម ជាមួយនឹងកែ ពក, រវាង អ៊ុំ ស៊ីម ជាមួយនឹង តា ម៉ុក, រវាង កែ ពក ជាមួយនឹង តា ម៉ុក ឬរវាង អ៊ុំ ស៊ីម ជាមួយនឹងអ្នកក្រោមបង្គាប់គាត់។

ខ) កំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយនិរសារ អ្នកបើកបរ និងប្រតិបត្តិករទូរលេខផ្សេងទៀតដែលអាចមានព័ត៌មានអំពីការប្រាស្រ័យទាក់ទងគ្នានៅតំបន់ ៤៣។

គ) កំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយសាក្សីដែលអាចមានព័ត៌មានអំពីរចនាសម្ព័ន្ធធ្វើសេចក្តីសម្រេច និងខ្សែរយៈបញ្ជាការនៅតំបន់ ៤៣ ហើយអាចកំណត់អត្តសញ្ញាណសមាជិកគ្រួសារផ្សេងទៀតដែលកាន់តំណែងមានសិទ្ធិអំណាច។

ឃ) កំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយសមាជិកគ្រួសារទាំងអស់របស់ កែ ពក និង តា ម៉ុក ដែលមានតំណែងផ្លូវការ ឬមិនផ្លូវការនៅតំបន់ ៤៣[12]។

១១. មេធាវីការពារក្តី អះអាងថា កិច្ចស៊ើបសួរទាំងនេះទំនងជានាំឱ្យរកឃើញភស្តុតាងដោះបន្ទុកជាបឋម ទាក់ទងនឹងការចោទប្រកាន់ថា អោ អាន បានបញ្ជាឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មមួយចំនួននៅតំបន់ទាំងនោះ ព្រមទាំងការចោទប្រកាន់ថា គាត់មានការគ្រប់គ្រងដ៏មានប្រសិទ្ធភាព

---

[10] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣១។

[11] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣៣-៣៦

[12] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣៥។

មកលើភូមិភាគកណ្តាល និងតំបន់នីមួយៗ[13]។ ជាពិសេស មេធាវីការពារក្តី អះអាងថា សំណើនឹងជួយទម្លាក់ករណីរបស់មេធាវីការពារក្តី ដែលថា អោ អាន មិនបានដឹងឮអំពីបញ្ហាសន្តិសុខ ឬក៏មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចលើបញ្ហាសន្តិសុខនៅភូមិភាគកណ្តាល និងតំបន់ ៤១, ៤២ និង ៤៣ ឡើយ[14]។

## III. ពិភាក្សា

១២. អង្គបុរេជំនុំជម្រះធ្លាប់បានបញ្ជាក់ថា ភាគីដែលស្នើសុំបំពេញកិច្ចស៊ើបសួរ"ត្រូវបំពេញលក្ខខណ្ឌត្រួតលើគ្នាចំនួនពីរ [...] ពោលគឺ សំណើសុំត្រូវតែ៖

*(១) កំណត់បង្ហាញអំពីសកម្មភាពដែលត្រូវធ្វើ ឬដីកាដែលត្រូវធ្វើ ដោយមានការបញ្ជាក់ឱ្យបានច្បាស់លាស់("លក្ខខណ្ឌនៃភាពច្បាស់លាស់") និង*

*(២) បង្ហាញឱ្យបានពិស្តារអំពីមូលហេតុអ្វីបានជាសំណើបំពេញកិច្ចស៊ើបសួរដែលបានស្នើសុំ ឬកិច្ចដែលកើតចេញមកពីដីកាដែលធ្វើឡើង អនុលោមតាមវិធាន ៥៥(១០)នៃវិធានផ្ទៃក្នុង មានការ"ពាក់ព័ន្ធទៅនឹងការបញ្ជាក់នូវការពិត"ជាបឋម(លក្ខខណ្ឌនៃភាពពាក់ព័ន្ធជាបឋម)"*[15]។

១៣. លក្ខខណ្ឌនៃភាពច្បាស់លាស់ តម្រូវឱ្យភាគីដែលស្នើ ជាប់កាតព្វកិច្ច"*ត្រូវមានភាពច្បាស់លាស់គ្រប់គ្រាន់ដើម្បីធ្វើការបង្ហាញឱ្យបានច្បាស់លាស់ដល់សហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធនឹងកិច្ចការអ្វីដែលសហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបសួរ*"[16]។ ហេតុនេះ ខ្ញុំមិនជាប់លក្ខខណ្ឌត្រូវអនុញ្ញាតតាមសំណើមានលក្ខណៈជាទូទៅ ឬប៉ាន់ស្មាន ដែលស្នើសុំស្វែងរកភស្តុតាង

---

[13]ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៧,៣២ និង ៣៦។

[14]ដូចជើងទំព័រខាងលើ កថាខណ្ឌ ២ និង ២១។

[15]សំណុំរឿង ០០២ ឯកសារ D365/2/17 *សាលដីកាស្តីពីការពិចារណាឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង* ("សាលដីកាស្តីពីការពិចារណាឡើងវិញ") ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ៤៧។

[16]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៨។

ដោះបន្ទុកឡើយ[17]។ ប៉ុន្តែ ភាគីដែលស្នើ ត្រូវតែចង្អុលបង្ហាញឱ្យបានច្បាស់លាស់អំពីវត្តមាននៃភស្តុតាងដែលត្រូវស្វែងរក[18]។ ឧទាហរណ៍ អ.ប.ជ បានសម្រេចថា សំណើសុំដែលមិនបានលើកឡើងច្បាស់លាស់អំពីចំនួនឯកសារ ឬអំពីទីតាំងច្បាស់លាស់ដែលប្រមូលបានឯកសារនោះ ឬទីតាំងទុកដាក់ឯកសារនោះ គឺខកខានមិនបានបំពេញលក្ខខណ្ឌនៃភាពច្បាស់លាស់ឡើយ[19]។

១៤. លក្ខខណ្ឌនៃភាពពាក់ព័ន្ធ មានលក្ខខណ្ឌរងចំនួនពីរ។ ទី ១ សំណើ ត្រូវ"*មានការពាក់ព័ន្ធជាមួយនឹងវិសាលភាពនៃការស៊ើបសួរ អនុលោមតាមការកំណត់ និងព្រំដែនដែលបានកំណត់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម*"[20]។ ទី ២ សំណើ "*ត្រូវរៀបរាប់លម្អិតអំពីមូលហេតុអ្វីបានជាកិច្ចស្នើដែលជាកម្មវត្ថុនៃដីកាសម្រេចនឹងនាំឱ្យរកឃើញនូវការពិត*"[21]។ លក្ខខណ្ឌនេះតម្រូវថា ភាគីដែលស្នើសុំ ត្រូវបញ្ជាក់ពីចំណងទាក់ទងជាបឋមរវាងកិច្ចស៊ើបសួរដែលបានស្នើសុំ ជាមួយនឹងបញ្ហាដែលស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ[22]។ ក្នុងករណីដែលសំណើពាក់ព័ន្ធនឹងភស្តុតាងដោះបន្ទុក ភាគីដែលស្នើសុំត្រូវបង្ហាញពីមូលហេតុជាបឋមដែលថា ការបំពេញកិច្ចស៊ើបសួរអាចនាំឱ្យមានភស្តុតាងដោះបន្ទុក[23]។

---

[17]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៤៨ និង ៥១។

[18]សំណុំរឿង០០២ ឯកសារ D100/9/2 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើលើកទីពីររបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៣១។ សំណុំរឿង០០២ ឯកសារD164/4/13 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួមរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើលើកទីពីររបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៣៨-៣៩។ សំណុំរឿង០០២ ឯកសារ D273/3/5 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស លើសំណើលើកទី ១៨ របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ១៩-២០, ២៦ និង ២៩។ សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៨ និង ៧៣។

[19]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៨។

[20]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៤៩។

[21]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៥០។

[22]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៥០-៥១។

[23]សំណុំរឿង០០២ ឯកសារ D353/2/3 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ"ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១០* ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៤៧។

## ក. តំបន់ ៤១

*ក) ស៊ើបសួរថាតើ អ៊ុំ ស៊ីម នៅរស់ ឬស្លាប់ ហើយបើនៅរស់ ស្តាប់ចម្លើយគាត់ទាក់ទងនឹងប្រធានបទជាក់លាក់មួយចំនួន*

១៥. នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានស្តាប់ចម្លើយប្រពន្ធរបស់ អ៊ុំ ស៊ីម ឈ្មោះ តូ សេម ហើយគាត់បានបញ្ជាក់ថា អ៊ុំ ស៊ីម បានស្លាប់ហើយ[24]។ គាត់បានបញ្ជាក់ទៀតថា គាត់មិនមានសំបុត្រមរណភាពទេ ពីព្រោះថា គាត់មិនដែលបានសុំ[25]។ មិនមានកាលៈទេសៈដែលបង្ហាញថា តូ សេម អាចកុហកឡើយទាក់ទងនឹងការស្លាប់របស់ប្តីគាត់។ ហេតុនេះ ខ្ញុំជឿថា អ៊ុំ ស៊ីម បានស្លាប់ហើយ ហើយខ្ញុំមិនយល់ឃើញថាចាំបាច់ត្រូវស៊ើបអង្កេតថែមទៀតទេអំពីអង្គហេតុនៃការស្លាប់របស់គាត់។

*ខ) កំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយសាក្សី ដូចជា តូ សម ទាក់ទងនឹងសិទ្ធិអំណាច និងអំណាចធ្វើសេចក្តីសម្រេចជាក់ស្តែងរបស់ អ៊ុំ ស៊ីម នៅតំបន់ ៤១ ទំនាក់ទំនងរបស់ អ៊ុំ ស៊ីម ជាមួយកែ ពក និងថាតើគាត់បានបន្តធ្វើរបាយការណ៍ទៅ តា ម៉ុក ទទួលបញ្ជាពី តា ម៉ុក ឬរក្សាទំនាក់ទំនងជាមួយ តា ម៉ុក ក្រោយពេលគាត់ត្រូវបានបញ្ជូនទៅភូមិភាគកណ្តាល*

១៦. មេធាវីការពារក្តី មិនបានកំណត់អត្តសញ្ញាណសាក្សីណាដែលត្រូវស្តាប់ចម្លើយឡើយ ប៉ុន្តែបែរជាស្នើខ្ញុំ ឱ្យកំណត់អត្តសញ្ញាណសាក្សីដូចជា តូ សេម ហើយស្តាប់ចម្លើយសាក្សីទាំងនោះអំពីការចូលរួមរបស់ អ៊ុំ ស៊ីម នៅក្នុងតំបន់ ៤១។

១៧. អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានស្តាប់ចម្លើយ តូ សេម បន្ទាប់ពីមេធាវីការពារក្តី បានដាក់សំណើ។ គាត់បានបញ្ជាក់ថា ខ្មោចប្តីគាត់ឈ្មោះ អ៊ុំ ស៊ីម ឧស្សាហ៍ប្រជុំជាមួយនឹងកែ ពក

---

[24]សំណុំរឿង ០០៤ ឯកសារ D219/677 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តូ សេម* ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឆ.១-ឆ.៣។ សំណុំរឿង ០០៤ ឯកសារ D219/677.1 *ឯកសារភ្ជាប់៖ រូបថត អ៊ុំ ស៊ីម* ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ ២០១៦។ សំណុំរឿង ០០៤ ឯកសារ D119/70/3 *មជ្ឈមណ្ឌលឯកសារកម្ពុជា សម្ភាសន៍ជាមួយ តូ សេម* ថ្ងៃទី១៨ ខែ សីហា ឆ្នាំ ២០១៣ ទំព័រ ២។ ការស្លាប់នេះក៏មានការបញ្ជាក់ពី ទេព ប៊ុច៖ សំណុំរឿង ០០៤ ឯកសារ D117/19 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេព ប៊ុច* ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣។

[25]សំណុំរឿង ០០៤ ឯកសារ D219/677 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តូ សេម* ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឆ.១។

ប៉ុន្តែ គាត់មិនអាចផ្តល់ព័ត៌មានលម្អិតជាក់លាក់អំពីខ្លឹមសារនៃអង្គប្រជុំទាំងបាននោះទេ[26]។ គូ សេម បានបញ្ជាក់ថា គាត់ និងប្តីគាត់ឈ្មោះ អ៊ុំ ស៊ីម នៅបន្តរាយការណ៍ទៅ តា ម៉ុក ក្រោយពេលមកដល់ភូមិភាគកណ្តាល ប៉ុន្តែ គាត់មិនអាចផ្តល់កាលបរិច្ឆេទជាក់លាក់ និងព័ត៌មានលម្អិតអំពីរបាយការណ៍ទាំងនោះបានទេ[27]។ ដោយផ្អែកលើចម្លើយទាំងនេះ ខ្ញុំមិនជឿថា គូ សេម អាចផ្តល់ភស្តុតាងកាន់តែលម្អិតអំពីសិទ្ធិអំណាច និងអំណាចធ្វើសេចក្តីសម្រេចជាក់ស្តែងរបស់ប្តីគាត់ នៅតំបន់ ៤១ ឬក៏អំពីទំនាក់ទំនងរបស់ប្តីគាត់ជាមួយនឹង កែ ពក និង តា ម៉ុក បានឡើយ។

១៨. ផ្នែកផ្សេងទៀតទាំងអស់នៃសំណើត្រង់នេះ គឺមិនមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់អាចឱ្យខ្ញុំពិចារណាឱ្យបានត្រឹមត្រូវបានឡើយ។ មេធាវីការពារក្តី ត្រូវផ្តល់ព័ត៌មានច្បាស់លាស់ឱ្យបានគ្រប់គ្រាន់ដើម្បីបង្ហាញឱ្យបានច្បាស់អំពីកិច្ចស៊ើបស៊ើបអ្វីដែលខ្លួនស្នើសុំឱ្យ ស.ច.ស បំពេញ[28]។ នៅក្នុងអំឡុងពេលស៊ើបសួរ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានស្តាប់ចម្លើយសាក្សីជាច្រើននាក់ទាក់ទងនឹងសិទ្ធិអំណាច និងអំណាចធ្វើសេចក្តីសម្រេចជាក់ស្តែងរបស់ អ៊ុំ ស៊ីម នៅតំបន់ ៤១[29]។ ក្នុងករណីដែលពាក់ព័ន្ធ អ្នកស៊ើបអង្កេត ក៏បានសាកសួរសាក្សី អំពីទំនាក់

---

[26]ដូចជើងទំព័រខាងលើ ធ. ៨។

[27]សំណុំរឿង ០០៤ ឯកសារ D219/677 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គូ សេម* ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ធ.១៨-ធ.២០។

[28]សំណុំរឿង០០២ ឯកសារD164/3/6 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម* ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៤០-៤៥។ សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៨។

[29]សំណុំរឿង០០៤ ឯកសារ D117/70 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត* ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៣ ធ.២៣-ធ.២៤។ សំណុំរឿង០០៤ ឯកសារ D117/71 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត* ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ ធ.១៤។ សំណុំរឿង០០៤ ឯកសារ D117/72 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត* ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៣ ធ.១-ធ.២។ សំណុំរឿង០០៤ ឯកសារ D117/18 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម* ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ធ.១ និង ធ.១៥។ សំណុំរឿង០០៤ ឯកសារ D117/19 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេព ប៉ូច* ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣ ធ.១២-ធ.១៣។ សំណុំរឿង០០៤ ឯកសារ D117/50 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម ប៉ុន* ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៤ ធ.១៥, ធ.១៧-ធ.១៨, ធ.២៣, ធ.៥៥-ធ.៥៦។ សំណុំរឿង០០៤ ឯកសារ D219/249 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល* ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៥ ធ.១ និង ធ.៤។ សំណុំរឿង០០៤ ឯកសារ D117/56 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ វង្ស ហៅ យក់ ង៉ូវ ឬង៉ូវ* ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ធ.១០, ធ.២៥-ធ.២៦ និង ធ.៣១។ សំណុំរឿង០០៤ ឯកសារ

ទំនងរបស់ អ៊ុំ ស៊ីម ជាមួយនឹង កែ ពក[30] ផងដែរ និងសាកសួរថាតើ គាត់នៅបន្តរាយការណ៍ទៅ តា ម៉ុក ទទួលបញ្ជាពី តា ម៉ុក ឬរក្សាទំនាក់ទំនងជាមួយនឹង តា ម៉ុក ដែរឬអត់បន្ទាប់ពីគាត់ត្រូវបានបញ្ជូនទៅភូមិភាគកណ្តាល[31]។ ដូចខ្ញុំបានបញ្ជាក់ខាងលើដែរ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស នឹងបន្តស្វែងរកភស្តុតាងដែលពាក់ព័ន្ធនឹងរចនាសម្ព័ន្ធធ្វើសេចក្តីសម្រេចនៅតំបន់ ៤១ រាប់បញ្ចូលទាំងតួនាទីរបស់ អ៊ុំ ស៊ីម នៅក្នុងតំបន់នេះ។

*គ) ស្តាប់ចម្លើយ តូ សេម ឡើងវិញ ដើម្បីផ្តល់ព័ត៌មានអំពីបញ្ហាផ្សេងៗ*

១៩. មេធាវីការពារក្តី ស្នើថា ស.ច.ស គួរស្តាប់ចម្លើយ តូ សេម ឡើងវិញ ដើម្បីផ្តល់ព័ត៌មានអំពី៖ (១) ទំនាក់ទំនងគ្រួសារគាត់ជាមួយនឹង តា ម៉ុក និងតួនាទីរបស់ តូ សេម នៅក្នុងរចនាសម្ព័ន្ធខ្មែរក្រហម (២) ទំនាក់ទំនងរបស់គាត់ និងប្តីគាត់ ជាមួយនឹង កែ ពក (៣) ការបន្តការប្រាស្រ័យទាក់ទងគ្នារវាងគាត់ ឬប្តីគាត់ ជាមួយនឹង តា ម៉ុក (៤) សិទ្ធិអំណាច និងអំណាចធ្វើសេចក្តីសម្រេចជាក់ស្តែងរបស់ អ៊ុំ ស៊ីម (៥) ការបញ្ជាក់របស់ អ៊ុំ ស៊ីម អំពីការឡើងឋានៈ

---

D117/35 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៤ ឆ.១៣-ឆ.១៥ និង ឆ.៦៣។ សំណុំរឿង០០៤ ឯកសារ D219/711 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈន ប៊ិច* ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឆ.៤៤។ សំណុំរឿង០០៤ ឯកសារD117/26 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុត កុល* ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៣ ឆ.២៨។ សំណុំរឿង០០៤ ឯកសារ D107/15 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ៣។ សំណុំរឿង០០៤ ឯកសារ D219/442 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ វង្ស ហៅ យក់ ង៉ូវ* ឬង៉ូវ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៥ ឆ.៧៨-ឆ.៨០, ឆ.១០៣ និង ឆ.១១៥។ សំណុំរឿង០០៤ ឯកសារ D219/687 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ៅ សារឿន* ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឆ.៣២។

[30]សំណុំរឿង០០៤ ឯកសារ D219/353 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សារ៉ាយ ហៀន* ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥ ឆ.៣-ឆ.៤ និង ឆ.៦។ សំណុំរឿង០០៤ ឯកសារ D219/249 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្លួន កាឝិល* ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៥ ឆ.១ និង ឆ.៤។ សំណុំរឿង០០៤ ឯកសារ D117/35 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៤ ឆ.១៣-ឆ.១៥។ សំណុំរឿង០០៤ ឯកសារ D107/15 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ៣។ សំណុំរឿង០០៤ ឯកសារ D219/178 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុច រ៉ា* ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.៥។ សំណុំរឿង០០៤ ឯកសារ D219/762, *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សារ៉ាយ ហៀន* ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ ឆ.៣៣-ឆ.៣៤ និង ឆ.១២៣-ឆ.១២៥។

[31]សំណុំរឿង ០០៤ ឯកសារ D219/677 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តូ សេម* ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឆ.១៨-ឆ.២០។

របស់គាត់ទៅជាលេខាតំបន់ ៤៣ និងអនុលេខាភូមិភាគកណ្តាល (៦) ឈ្មោះអ្នកក្រោមបង្គាប់របស់ អ៊ុំ ស៊ីម រួមមាននិរសារ អ្នកបើកបរ និងអង្គរក្ស (៧) អង្គប្រជុំដែលធ្វើឡើងដោយ អ៊ុំ ស៊ីម និង (៨) សិទ្ធិអំណាចជាក់ស្តែងជាសក្តានុពលរបស់ ប្រាក់ យុត[32]។

២០. អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានស្តាប់ចម្លើយ តូ សេម នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ហើយបានសួរគាត់អំពីបញ្ហាដែលបានលើកឡើងនៅក្នុងសំណើត្រង់ចំណុចនេះ[33]។

*ឃ) ដាក់ចូលក្នុងសំណុំរឿងនូវរូបថតរបស់ អ៊ុំ ស៊ីម ដែល តូ សេម ឬមជ្ឈមណ្ឌលឯកសារកម្ពុជាអាចមាន*

២១. នៅក្នុងអំឡុងពេលស្តាប់ចម្លើយគាត់នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ តូ សេម បានបង្ហាញរូបថតប្តីគាត់មួយសន្លឹក ហើយអ្នកស៊ើបអង្កេត បានថតរូបថតនោះ ហើយរូបថតនោះបានដាក់បន្ថែមចូលក្នុងសំណុំរឿងរួចហើយ[34]។

*ង. កំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយសមាជិកគ្រួសាររបស់ តូ សេម និង អ៊ុំ ស៊ីម រួមមាន តា សន, យាយ ម៉ែន, អ៊ុំ ផន(ប), អ៊ុំ ផន (ស), អ៊ុំ ផុន(ស), អ៊ុំ ឃឿង, តា សឿ, តូ ស៊ីម, តូ រ៉ុំ, និង តូ ស៊ុន*

២២. បើយោងតាមសាក្សី ឃុន សារ៉េត បានឲ្យដឹងថា តា សន បានស្លាប់ហើយ[35]។ ហេតុនេះ មិនអាចស្តាប់ចម្លើយគាត់ បានឡើយ។

២៣. មេធាវីការពារក្តី មានបន្ទុកត្រូវបង្ហាញអំពីចំណងពាក់ព័ន្ធជាបឋមរវាងកិច្ចស៊ើបសួរដែលបានស្នើ ជាមួយនឹងបញ្ហាដែលស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ[36]។ ម្យ៉ាងទៀត មេធាវី

---

[32]សំណើ កថាខណ្ឌ ២៦។

[33]សំណុំរឿង០០៤ ឯកសារD219/677 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តូ សេម* ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឆ.៣-ឆ.៥, ឆ.៦-ឆ.៧, ឆ.១២, ឆ.១៧-ឆ.២០, ឆ.២២-ឆ.២៨, ឆ.៣០-ឆ.៣៣ និងឆ.៣៥-ឆ.៣៦។

[34]សំណុំរឿង០០៤ ឯកសារD219/677 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តូ សេម* ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឆ.៣-ឆ.៥។ សំណុំរឿង ០០៤ ឯកសារ D219/677.1 *ឯកសារភ្ជាប់៖ រូបថត អ៊ុំ ស៊ីម* ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ ២០១៦។

[35]សំណុំរឿង០០៤ ឯកសារ D1.3.11.22 *ក.ស.ព កំណត់ហេតុនៃកិច្ចសម្ភាសន៍ជាមួយ ឃុន សារ៉េត* ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៥។

ការពារក្តី ត្រូវតែផ្តល់សំអាងហេតុជាបឋមថា ជនដែលខ្លួនស្នើឱ្យ ស.ច.ស ស្តាប់ចម្លើយ អាចផ្តល់ភស្តុតាងដែលទាក់ទងនឹងការចោទប្រកាន់ប្រឆាំង អោ អាន[37]។

២៤. សំអាងហេតុដែលមេធាវីការពារក្តី បានផ្តល់ដើម្បីស្តាប់ចម្លើយ យាយ ម៉ែន, អ៊ុំ ថន(ប), អ៊ុំ ថន (ស្រី), អ៊ុំ ធុន, អ៊ុំ ឃឿង, តា សឿ, តូ ស៊ីម, តូ រ៉ុ, និង តូ ស៊ុន គឺថា អ្នកទាំងនោះគឺជាបងប្អូនរបស់ អ៊ុំ ស៊ីម ហេតុនេះ អ្នកទាំងនោះអាចមានព័ត៍មានអំពីតួនាទីរបស់គាត់នៅតំបន់៤១[38]។ ខ្ញុំជឿថា សាច់ញាតិជាទូទៅនៅក្នុងគ្រួសាររបស់ តូ សេម និង អ៊ុំ ស៊ីម បូករួមជាមួយនឹងភស្តុតាងមួយចំនួនដែលបង្ហាញថា តា ម៉ុក និង កែ ពក បានតែងតាំងសាច់ញាតិខ្លះឱ្យកាន់តំណែងនៅតំបន់៤១[39] គឺមិនមែនជាភាពពាក់ព័ន្ធជាបឋមដើម្បីស្តាប់ចម្លើយអ្នកទាំងនេះឡើយ[40]។ ហេតុនេះ សំណើត្រង់ផ្នែកនេះត្រូវបដិសេធ។

*ច) កំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយប្រតិបត្តិករទូរលេខ និងនិរសារ រួមមាន សួន កានិល, លីម សេង និង ប៉ុន អុល*

២៥. អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានស្តាប់ចម្លើយ សួន កានិល ជាច្រើនលើកអំពីការប្រាស្រ័យទាក់ទងគ្នារវាងភូមិភាគកណ្តាល ជាមួយនឹងតំបន់របស់ភូមិភាគនេះ[41]។ គាត់បាន

---

[36]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៥០-៥១។

[37]សំណុំរឿង០០២ ឯកសារ D273/3/5 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស លើសំណើលើកទី១៨ របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី១០ ខែ មិថុនា ឆ្នាំ២០១០ កថាខណ្ឌ២៦។ សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៥០-៥១ និង ៧៣-៧៤។ សំណុំរឿង០០២ ឯកសារ D164/3/6 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម* ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៣៩។

[38]សំណើ កថាខណ្ឌ ២៦។

[39]សំណើ កថាខណ្ឌ ១៥-១៧ និង ២៣-២៤។

[40]សំណុំរឿង០០២ ឯកសារ D353/2/3 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ"ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១០* ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៣៤, ៣៩-៤០ និង ៤៣។

[41]សំណុំរឿង០០៤ ឯកសារ D6.1.697 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល* ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩។ សំណុំរឿង០០៤ ឯកសារ D29 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល* ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១។ សំណុំរឿង០០៤ ឯកសារD219/249 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន កានិល* ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៥។

បញ្ជាក់ថា ការងាររបស់គាត់គឺពាក់ព័ន្ធនឹងការបញ្ជូន និងទទួលទូរលេខរវាងភូមិភាគកណ្ដាលជាមួយនឹងតំបន់របស់ភូមិភាគនេះ[42] ប៉ុន្តែ គាត់បានបញ្ជាក់ថា គាត់មិនបានដឹងថាតើទូរលេខទាំងនោះមានខ្លឹមសារយ៉ាងណា ឬញឹកញាប់ប៉ុនណាឡើយ ពីព្រោះថា ទូរលេខទាំងនោះជាប់លេខកូដ[43]។ គាត់ក៏បានលើកឡើងថា គាត់មិនបានចូលរួមអង្គប្រជុំថ្នាក់ភូមិភាគឡើយ ពីព្រោះថា គាត់គឺជាយុទ្ធជនថ្នាក់ទាប[44]។ ហេតុនេះ ខ្ញុំមិនជឿថា សួន កានិល អាចផ្ដល់ភស្តុតាងថែមទៀតអំពីអង្គប្រជុំ និងការប្រាស្រ័យទាក់ទងគ្នាដែលពាក់ព័ន្ធជាមួយនឹង កែ ពក, តា ម៉ុក, អ៊ុំ ស៊ឹម និងអ្នកក្រោមបង្គាប់របស់ អ៊ុំ ស៊ឹម ឡើយ។

២៦. អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ក៏បានស្ដាប់ចម្លើយ លឹម សេង[45] ដែលធ្លាប់ធ្វើជាអ្នកបកប្រែទូរលេខនៅមន្ទីរផ្សព្វផ្សាយរបស់ភូមិភាគកណ្ដាល តាំងពីឆ្នាំ ១៩៧៧[46]។ នៅចុងឆ្នាំ ១៩៧៧ គាត់ត្រូវបានចាត់តាំងឱ្យធ្វើជាអ្នកបើកឡានឱ្យ កែ ពក ហើយបានជូនដំណើរ កែ ពក ទៅតំបន់ផ្សេងៗដើម្បីចូលរួមអង្គប្រជុំ និងចុះមើលការដ្ឋាន[47]។ លឹម សេង ក៏បានបញ្ជាក់ថា លេខាតំបន់នឹងត្រូវកោះឱ្យមកចូលរួមអង្គប្រជុំនៅទីស្នាក់ការកណ្ដាលនៅភូមិភាគកណ្ដាល[48]។ ដោយសារថា លឹម សេង បានប្រាប់ ក.ស.ច.ស ថា គាត់មិនអាចចូលរួមអង្គប្រជុំណាមួយ

---

[42]សំណុំរឿង០០៤ ឯកសារ D6.1.697 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួន កានិល* ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ៦-៨ និងទំព័រ ១១។ សំណុំរឿង០០៤ ឯកសារ D29 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួន កានិល* ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ៣។ សំណុំរឿង០០៤ ឯកសារ D219/249 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួន កានិល* ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៥ ឆ.១។

[43]សំណុំរឿង០០៤ ឯកសារ D6.1.697 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួន កានិល* ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ ទំព័រ៦-៧។ សំណុំរឿង០០៤ ឯកសារ D29 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួន កានិល* ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ៤។ សំណុំរឿង០០៤ ឯកសារ D219/249 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួន កានិល* ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៥ ឆ.១។

[44]សំណុំរឿង០០៤ ឯកសារ D219/249 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួន កានិល* ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៥ ឆ.៧។

[45]សំណុំរឿង០០៤ ឯកសារ D117/20 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លឹម សេង* ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៣។

[46]ដូចជើងទំព័រខាងលើ ឆ.១។

[47]ដូចជើងទំព័រខាងលើ ឆ.១ និង ឆ.៧។

[48]ដូចជើងទំព័រខាងលើ ឆ.៧។

របស់ កែ ពក បានឡើយ ទើបមិនទំនងជាថា គាត់អាចផ្តល់ព័ត៌មានថែមទៀតអំពីខ្លឹមសារអង្គប្រជុំរវាងភាគីផ្សេងៗដែលមេធាវីការពារក្តី បានលើកឡើងនោះឡើយ[49]។

២៧. អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានស្តាប់ចម្លើយ ប៊ុន អុល ចំនួនពីរលើក[50]។ ចាប់ពីឆ្នាំ ១៩៧៦ គាត់ធ្វើការនៅផ្នែកទូរលេខភូមិភាគកណ្តាល ដែលបញ្ជូន និងទទួលទូរលេខរវាងភូមិភាគ ជាមួយនឹងតំបន់[51]។ គាត់ទទួលស្គាល់ថា គាត់បានទទួលសាររវាងពី ៤ ទៅ ៥ សារក្នុងមួយថ្ងៃ ភាគច្រើនមកពីមជ្ឈិម ប៉ុន្តែ គាត់បានបញ្ជាក់ថា គាត់មិនបានដឹងអំពីខ្លឹមសារនៃសារទាំងនោះឡើយ ពីព្រោះថា សារទាំងនោះជាប់លេខកូដ[52]។ គាត់ក៏បង្ហាញឲ្យឃើញថាគាត់ដឹងមានកម្រិតអំពីតួនាទី និងសិទ្ធិអំណាចជាក់លាក់របស់សមាជិកជាន់ខ្ពស់បំផុតនៅគណៈភូមិភាគកណ្តាល[53]។ ហេតុនេះ មិនមានមូលហេតុជឿថា ប៊ុន អុល អាចផ្តល់ព័ត៌មានថែមទៀតអំពីខ្លឹមសារនៃការប្រាស្រ័យទាក់ទងគ្នារវាងភាគីផ្សេងៗដែលមេធាវីការពារក្តី បានលើកឡើងនោះឡើយ[54]។

២៨. តាមសំអាងហេតុទាំងនេះ ខ្ញុំមិនយល់ឃើញថាចាំបាច់ត្រូវធ្វើការស្តាប់ចម្លើយថែមទៀតឡើយ ជាមួយនឹងសាក្សីណាម្នាក់ក្នុងចំណោមសាក្សីទាំងបីនាក់នេះ។ ដូចខ្ញុំបានបង្ហាញខាងលើដែរ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស នឹងបន្តស្វែងរកឥតប្រុយទាក់ទងនឹងភស្តុតាងអំពីអង្គប្រជុំ

---

[49]ដូចជើងទំព័រខាងលើ ឆ.៨ និង ឆ.១០។

[50]សំណុំរឿង០០៤ ឯកសារ D6.1.373 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន អុល* ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៩។ សំណុំរឿង០០៤ ឯកសារ D117/30 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន អុល* ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០១៣។

[51]សំណុំរឿង០០៤ ឯកសារ D6.1.373 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន អុល* ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៣-៥។ សំណុំរឿង០០៤ ឯកសារ D117/30 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន អុល* ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឆ.១-ឆ.២។

[52]សំណុំរឿង០០៤ ឯកសារ D6.1.373 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន អុល* ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៣-៥។ សំណុំរឿង០០៤ ឯកសារ D117/30 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន អុល* ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឆ.២។

[53]សំណុំរឿង០០៤ ឯកសារ D117/30 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន អុល* ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឆ.៥។

[54]សំណុំរឿង០០៤ ឯកសារ D6.1.373 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន អុល* ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៤-៥។

និងការប្រាស្រ័យទាក់ទងគ្នារវាងមន្ត្រីថ្នាក់តំបន់ និងភូមិភាគ ត្រង់ចំណុចណាដែលភស្តុតាងនោះពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរ។

*ឆ) កំណត់អត្តសញ្ញាណ និងស្លាប់ចម្លើយសមាជិកគ្រួសារទាំងអស់របស់ កែ ពក និង តា ម៉ុក ដែលមានតំណែងផ្លូវការ ឬមិនផ្លូវការក្នុងតំបន់ ៤១*

២៩. វចនាសម្ព័ន្ធធ្វើសេចក្ដីសម្រេច និងខ្សែរយៈបញ្ជាការនៅតំបន់ ៤១ ទាំងជាក់ស្ដែង និងស្របច្បាប់ គឺជាចំណុចមួយដ៏សំខាន់នៃកិច្ចស៊ើបសួរសំណុំរឿង ០០៤។ ក្នុងករណីពាក់ព័ន្ធ ចំណុចនេះរាប់បញ្ចូលទាំងសក្ដានុពលនៃសិទ្ធិអំណាចស្របច្បាប់ និងជាក់ស្ដែងរបស់សមាជិកគ្រួសារ កែ ពក និង តា ម៉ុក[55]។

៣០. ប៉ុន្តែ សំណើសុំកំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយសមាជិកគ្រួសារទាំងអស់របស់ កែ ពក និងតា ម៉ុក ដែលមានតំណែងផ្លូវការ ឬមិនផ្លូវការនៅតំបន់ ៤១ គឺជាសំណើជារួមមាន

---

[55]តួនាទីរបស់ កែ ពក នៅភូមិភាគកណ្ដាល ឧទាហរណ៍សូមមើល សំណុំរឿង ០០៤ ឯកសារ D1.3.16.1 *ប្រវត្តិតស៊ូរបស់លោក កែ ពក "កែ ពក បានការពារខ្លួនមុនពេលស្លាប់* ERN 00164125-00164126។ សំណុំរឿង០០៤ ឯកសារ D219/249 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួន កានិល* ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៥ ឆ.១។ សំណុំរឿង០០៤ ឯកសារ D6.1.407 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ខិ ហូ* ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៤។ សំណុំរឿង ០០៤ ឯកសារ D1.3.11.7 *កំណត់ហេតុនៃកិច្ចសម្ភាសន៍ជាមួយ ចេង គុល និង គុណ សុខា* ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៣។ សំណុំរឿង០០៤ ឯកសារ D107/15 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ៣។ សំណុំរឿង០០៤ ឯកសារ D6.1.386 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ១២។ សំណុំរឿង០០៤ ឯកសារ D117/35 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៤ ឆ.១៣-ឆ.១៥។ សំណុំរឿង០០៤ ឯកសារ D219/41 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ផាន់ ឆេន* ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៤ ឆ.១២-ឆ.១៨។ សំណុំរឿង០០៤ ឯកសារ D1.3.11.35 *កំណត់ហេតុនៃកិច្ចសម្ភាសន៍ជាមួយ នីវ ស៊ុន* ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ៦។ សំណុំរឿង០០៤ ឯកសារ D6.1.106 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សឡេះ អះម៉ាត់* ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៥។ សំណុំរឿង០០៤ ឯកសារ D40 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សឡេះ អះម៉ាត់* ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១១ ទំព័រ ៥។ សំណុំរឿង០០៤ ឯកសារ D119/70/3 សំណុំរឿង ០០៤ ឯកសារ D119/70/3 *មជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍ជាមួយ តូ សេម* ថ្ងៃទី១៨ ខែ សីហា ឆ្នាំ ២០១៣ ទំព័រ ៥៣។ តួនាទីរបស់ កែ ពក នៅភូមិភាគកណ្ដាល សូមមើល ឧទាហរណ៍សំណុំរឿង ០០៤ ឯកសារ D219/138 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យូ វ៉ាន់* ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥ ឆ.៦៣។ សំណុំរឿង០០៤ ឯកសារ D118/259 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពេជ្រ ជីម ចុះថ្ងៃទី ១៩-០៦-២០១៤* ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.៥៦ និង ឆ.១៦៩។

លក្ខណៈទូទៅ។ ខ្ញុំមិនមានគម្រោងចំណាយធនធានដើម្បីបំពេញកិច្ចស៊ើបសួរដែលត្រូវការងារយ៉ាងច្រើនបែបនេះឡើយ ប្រសិនគ្មានការបង្ហាញឱ្យច្បាស់ជាងនេះថា សាច់ញាតិមួយចំនួនដែល ក.ស.ច.ស មិនទាន់បានស្តាប់ចម្លើយ អាចមានព័ត៌មានពាក់ព័ន្ធនឹងសិទ្ធិអំណាចធ្វើសេចក្តីសម្រេចរបស់ អោ អាន នៅតំបន់ ៤១។

## ខ. តំបន់ ៤២

*ក) ស្តាប់ចម្លើយឡើងវិញចំពោះឈ្មោះ ទេព ប៉ូច, បាន សៀក និង ស៊ូ សឿន*

៣១. មេធាវីការពារក្តី អះអាងថា ការស្តាប់ចម្លើយឡើងវិញចំពោះឈ្មោះ ទេព ប៉ូច, បាន សៀក និង ស៊ូ សឿន គឺជាការចាំបាច់ដើម្បីទទួលបានព័ត៌មានទាក់ទងនឹងប្រធានបទចំនួនប្រាំ គឺ (១) បញ្ជាក់បំភ្លឺអំពីរចនាសម្ព័ន្ធធ្វើសេចក្តីសម្រេច និងខ្សែរយៈបញ្ជាការជាក់ស្តែងនៅតំបន់ ៤២ (២)ស្វែងរកឈ្មោះសមាជិកគណៈស្រុក និងឃុំទាំងអស់ (៣)ពន្យល់អំពីការទទួលខុសត្រូវជាក់លាក់របស់ឈ្មោះ អឿន និង ស៊ូ សឿន ទាក់ទងនឹងកិច្ចការនយោបាយ និងសន្តិសុខ (៤) ស្វែងរកការប្រាស្រ័យទាក់ទងគ្នារវាង កែ ពក ជាមួយនឹងសមាជិកគ្រួសារគាត់ និង (៥) កំណត់អត្តសញ្ញាណបុគ្គលដទៃទៀតដែលដឹងព័ត៌មានពាក់ព័ន្ធ[56]។

៣២. ចំពោះប្រធានបទទី ២, ៤ និង ៥ មេធាវីការពារក្តី មិនបានបំពេញតាមលក្ខខណ្ឌតម្រូវផ្នែកច្បាស់លាស់ និង/ឬភាពពាក់ព័ន្ធជាបឋមឡើយ។

៣៣. ចំពោះប្រធានបទទី ២, ខ្ញុំមិនជឿថា នៅពេលនេះ ចាំបាច់ត្រូវស្វែងរកឈ្មោះសមាជិកគណៈស្រុក និងឃុំទាំងអស់ នៅតំបន់ ៤២ ឡើយ។ នៅក្នុងតំបន់ ៤២ អោ អាន ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យ[57]ពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខចម្ការស្វាយចន្ទី នៅឃុំស្វាយទាប ស្រុកចម្ការលើ[58] និងនៅមន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក នៅឃុំបល្ល័ង្ក

---

[56]សំណើ កថាខណ្ឌ ៣១។

[57]សំណុំរឿង០០៤ ឯកសារD303 *កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀតរបស់ អោ អាន* ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦។

[58]សំណុំរឿង០០៤ ឯកសារ D107/17 *របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១២៖ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង* ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ១។

ស្រុកបារាយណ៍[59]។ ដីកាសន្និដ្ឋានទី ៣ ចោទថែមទៀតថា អោ អាន ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខវត្តកណ្តាល នៅឃុំច្រនៀង ស្រុកបារាយណ៍[60]។ ក.ស.ច.ស បានស៊ើបអង្កេតសមាសភាពគណៈឃុំ និងគណៈស្រុក នៅទីតាំងទាំងនោះ ហើយនឹងបន្តស៊ើបអង្កេតក្នុងកម្រិតដែលពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ[61]។ ហេតុនេះ ខ្ញុំរំឭកថា នៅក្នុង*សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ* ខ្ញុំបានជូនដំណឹងភាគីទាំងអស់ថា ខ្ញុំនឹងមិនស៊ើបអង្កេតថែមទៀតលើការចោទប្រកាន់ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនៅតំបន់ ៤២ និងតំបន់ ៤៣ ឡើយ ប៉ុន្តែអាចបើកកិច្ចស៊ើបសួរឡើងវិញប្រសិនបើកាលៈទេសៈតម្រូវឱ្យធ្វើដូច្នេះ[62]។ ហេតុនេះ ខ្ញុំនឹងមិនចំណាយធនធានថែមទៀតដើម្បីស៊ើបអង្កេតសមាសភាពគណៈឃុំ និងគណៈស្រុកនៅតំបន់ ៤២ ឡើយ ប្រសិនបើខ្ញុំមិនយល់ឃើញថា បញ្ហានេះមិនពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ អោ អាន ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅតំបន់ ៤១ ឬក៏ការចោទប្រកាន់ដែលនៅសេសសល់ទាំងអស់អំពីអំពើប្រល័យពូជសាសន៍ជនជាតិចាម នៅកំពង់ចាម។

៣៤. ចំពោះប្រធានបទទី ៤ សំណើទូទៅសុំស្វែងរកការប្រាស្រ័យទាក់ទងគ្នារវាង កែ ពក ជាមួយនឹងសមាជិកគ្រួសារគាត់ គឺជាសំណើមានលក្ខណៈទូទៅពេកយ៉ាងច្បាស់ ហើយមេធាវីការពារ

---

[59]សំណុំរឿង០០៤ ឯកសារ D6.1.391 *របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៩៖ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង* ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ២។

[60]សំណុំរឿង០០៤ ឯកសារ D1 *[កែតម្រូវ] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០-១១-២០០៨* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ កថាខណ្ឌ ៥២។ សំណុំរឿង០០៤ ឯកសារ D117/16 *របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២៖ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខវត្តកណ្តាល* ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ ទំព័រ ២-៣។ សំណុំរឿង០០៤ ឯកសារ D117/5 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ រឹម* ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ ទំព័រ ៣។ សំណុំរឿង០០៤ ឯកសារ D117/2 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុន* ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ ទំព័រ ៣។

[61]សំណុំរឿង០០៤ ឯកសារ D6.1.386 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ១២។ សំណុំរឿង០០៤ ឯកសារ D107/15 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ៣-៤។ សំណុំរឿង០០៤ ឯកសារ D6.1.385 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ូ សឿន* ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៥។

[62]សំណុំរឿង០០៤ ឯកសារ D307/3 *សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ* ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦។

ក្ដី មិនបានបញ្ជាក់អំពីមូលហេតុដែលសាច់ញាតិរបស់ កែ ពក អាចមានព័ត៌មានពាក់ព័ន្ធនឹងសិទ្ធិអំណាចរបស់ អឿន ឬ ស៊ូ សឿន នៅក្នុងតំបន់ ៤២ ហើយមេធាវីការពារក្ដី ក៏មិនបានបញ្ជាក់អំពីមូលហេតុជាបឋម ដែល ទេព ប៉ូច, បាន សៀក និង ស៊ូ សឿន អាចផ្ដល់ភស្ដុតាងអំពីការប្រាស្រ័យទាក់ទងគ្នាបែបនោះឡើយ។

៣៥. ចំពោះប្រធានបទទី ៥ សំណើទូទៅសុំ*កំណត់អត្តសញ្ញាណបុគ្គលដទៃទៀតដែលដឹងព័ត៌មានពាក់ព័ន្ធ* គឺជាសំណើដែលមិនមានភាពច្បាស់លាស់គ្រប់គ្រាន់ទេ។ ការកំណត់អត្តសញ្ញាណបុគ្គលដែលដឹងព័ត៌មានពាក់ព័ន្ធនឹងការចោទប្រកាន់ រាប់បញ្ចូលទាំងសិទ្ធិអំណាចជាក់ស្ដែង គឺជាទម្លាប់ធម្មតានៅក្នុងផ្នែកមួយនៃការបំពេញកិច្ចស៊ើបសួរ ហើយកិច្ចខិតខំប្រឹងប្រែងដើម្បីកំណត់អត្តសញ្ញាណបុគ្គលបែបនោះនឹងបន្តអនុវត្តទៀត។

៣៦. ខ្ញុំយល់ឃើញថា ប្រធានបទទី ១ និង ៣ គឺច្បាស់លាស់គ្រប់គ្រាន់ និងជាប់ពាក់ព័ន្ធ ហើយខ្ញុំនឹងពិចារណាប្រធានបទទាំងនេះរួមគ្នា។

៣៧. អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានស្ដាប់ចម្លើយ ទេព ប៉ូច រួចហើយអំពី (១) រចនាសម្ព័ន្ធធ្វើសេចក្ដីសម្រេច និងខ្សែរយៈបញ្ជាការជាក់ស្ដែងនៅតំបន់ ៤២ និង (៣)ការទទួលខុសត្រូវជាក់លាក់របស់ឈ្មោះ អឿន និង ស៊ូ សឿន ទាក់ទងនឹងកិច្ចការនយោបាយ និងសន្តិសុខ[63]។ នៅពេលដែលសួរអំពីស្រុកដែលស្ថិតនៅតំបន់ ៤២ ទេព ប៉ូច មិនអាចចាំឈ្មោះសមាជិកគណៈស្រុកឡើយ[64]។ នៅពេលដែលសួរអំពីសហករណ៍ ឬឃុំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ នៅស្រុកបារាយណ៍ គាត់មិនបានចាំចំនួនសរុបទេ[65]។ នៅពេលដែលសួរអំពីមន្ទីរសន្តិសុខនៅស្រុកបារាយណ៍ គាត់ទទួលស្គាល់ថាមានមន្ទីរសន្តិសុខ ប៉ុន្តែបានបដិសេធថា

---

[63]សំណុំរឿង០០៤ ឯកសារ D6.1.384 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទេព ប៉ូច* ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៩។ សំណុំរឿង០០៤ ឯកសារ D117/19 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទេព ប៉ូច* ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣។

[64]សំណុំរឿង០០៤ ឯកសារ D6.1.384 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទេព ប៉ូច* ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៩។

[65]ដូចជើងទំព័រខាងលើ។

មិនបានដឹងអំពីដំណើរការមន្ទីរសន្តិសុខទាំងនោះឡើយ[66]។ គាត់ក៏បានបញ្ជាក់ថា គាត់មិនបានដឹងអ្វីទេអំពី"*ការបោសសម្អាតខ្មាំង*"នៅតំបន់ ៤២[67]។ ហេតុនេះ ការស្តាប់ចម្លើយ ទេព ប៉ូច ឡើងវិញ មិនទំនងជាអាចបញ្ជាក់បំភ្លឺបន្ថែមអំពីខ្សែរយៈបញ្ជាការជាក់ស្តែងនៅតំបន់ ៤២ ឡើយ។ ទេព ប៉ូច ក៏បានបដិសេធថាមិនបានដឹងថាតើ ស៊ូ សឿន ជានរណាដែរ[68] ហើយគាត់បានផ្តល់ព័ត៌មានតិចតួចទេអំពីឈ្មោះ អឿន[69]។ ហេតុនេះ ខ្ញុំមិនជឿថា ការស្តាប់ចម្លើយគាត់ឡើងវិញ នឹងផ្តល់ពន្លឺថែមទៀតអំពីការទទួលខុសត្រូវជាក់លាក់របស់ អឿន និង ស៊ូ សឿន ចំពោះកិច្ចការនយោបាយ និងសន្តិសុខឡើយ។

៣៨. ក.ស.ច.ស បានស្តាប់ចម្លើយ បាន សៀក ចំនួន៥ លើក។ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានសួរ បាន សៀក អំពីរចនាសម្ព័ន្ធចាត់តាំង និងខ្សែរយៈបញ្ជាការនៅតំបន់ ៤២[70] ព្រមទាំងការពាក់ព័ន្ធរបស់គាត់ជាមួយនឹង អឿន និង ស៊ូ សឿន[71]។ ចាប់តាំងពីពេលដែលមេធាវី

---

[66]ដូចជើងទំព័រខាងលើ ទំព័រ ៦ និង ៩។ សំណុំរឿង០០៤ ឯកសារ D117/19 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេព ប៉ូច* ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣ ឆ.៩-១០។

[67]សំណុំរឿង០០៤ ឯកសារ D6.1.384 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេព ប៉ូច* ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៥-៦។ សំណុំរឿង០០៤ ឯកសារ D219/234.2.1 *មជ្ឈមណ្ឌលឯកសារកម្ពុជា កិច្ចសម្ភាសន៍ជាមួយ ទេព ប៉ូច* ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៨ ទំព័រ ១៦។

[68]សំណុំរឿង០០៤ ឯកសារ D6.1.384 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេព ប៉ូច* ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៩។

[69]សំណុំរឿង០០៤ ឯកសារ D117/19 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេព ប៉ូច* ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣ ឆ.៦។

[70]សំណុំរឿង០០៤ ឯកសារ D107/15 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ២។ សំណុំរឿង០០៤ ឯកសារ D6.1.386 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ១២-១៤។ សំណុំរឿង០០៤ ឯកសារ D117/35 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៤ ទំព័រ ៥-៦។

[71]សំណុំរឿង០០៤ ឯកសារ D6.1.386 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៣ និង ១៣។ សំណុំរឿង០០៤ ឯកសារ D107/15 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ២។ សំណុំរឿង០០៤ ឯកសារ D117/35 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៤ ឆ.៩, ឆ.១០, ឆ.១២, ឆ.១៨-ឆ.១៩, ឆ.២៧ និង ឆ.៤០។ សំណុំរឿង០០៤ ឯកសារ D219/702.1.75 *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីសំណុំរឿង ០០២/០២ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥* ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ ទំព័រ ៩ ។

01336665



ការពារក្តី បានដាក់សំណើមក បាន សៀក ក៏បានផ្តល់សក្ខីកម្មរួចហើយនៅក្នុងសំណុំរឿង ០០២ អំពីប្រធានបទមួយចំនួន ដែលមេធាវីការពារក្តី បានស្នើសុំឱ្យ ក.ស.ច.ស ស៊ើបអង្កេតរាប់បញ្ចូលទាំងការឡើងឋានៈរបស់ អឿន[72]។ អំពីសកម្មភាពប្រចាំថ្ងៃរបស់ អឿន បាន សៀក បានបញ្ជាក់ថា មន្ទីររបស់គាត់ស្ថិតនៅចម្ងាយប្រហែលជាពីរគីឡូម៉ែត្រពីមន្ទីររបស់ អឿន ហើយមានទីតាំងនៅឃុំផ្សេងគ្នា[73] ទោះបីជាការបញ្ជាក់នេះផ្ទុយពីការស្តាប់ចម្លើយលើកមុនរបស់ ក.ស.ច.ស ដែលពេលនោះ បាន សៀក បានបញ្ជាក់ថា មន្ទីររបស់គាត់ មានចម្ងាយតែ ៥០០ ម៉ែត្រពីមន្ទីរតំបន់តែប៉ុណ្ណោះ[74]។

៣៩. បាន សៀក បានបញ្ជាក់ផងដែរថា ស៊ូ សឿន ទទួលបន្ទុកខាងកិច្ចការនយោបាយនៅស្រុកចម្ការលើ[75] ហើយការប្រជុំរបស់គាត់ ជាមួយ ស៊ូ សឿន គឺពាក់ព័ន្ធតែការងារនៅការដ្ឋានតែប៉ុណ្ណោះ មិនមែនពាក់ព័ន្ធនឹងការបោសសម្អាត ឬការចាប់ខ្លួនឡើយ[76]។ គាត់បានបញ្ជាក់ជាច្រើនលើកថា គាត់មិនបានដឹងអំពីបញ្ហាសន្តិសុខនៅតំបន់ ៤២ ឡើយ[77]។ គាត់បានបញ្ជាក់ផងដែរថា គាត់មិនបានចូលរួមអង្គប្រជុំណាមួយនៅថ្នាក់តំបន់ ៤២ ឡើយ[78]។ ហេតុនេះ ខ្ញុំមិន

---

[72]សំណុំរឿង០០៤ ឯកសារ D219/702.1.75 *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីសំណុំរឿង ០០២/០២ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥* ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ ទំព័រ ៩ និង ១៧។

[73]ដូចជើងទំព័រខាងលើ ទំព័រ ១៩ ។

[74]សំណុំរឿង០០៤ ឯកសារ D117/35 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៤ ឆ.១៩។

[75]សំណុំរឿង០០៤ ឯកសារ D107/15 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ៤។

[76]សំណុំរឿង០០៤ ឯកសារ D117/35 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៤ ឆ.២៧។

[77]សំណុំរឿង០០៤ ឯកសារ D6.1.386 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ១៣-១៤។ សំណុំរឿង០០៤ ឯកសារ D219/702.1.75 *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីសំណុំរឿង ០០២/០២ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥* ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ ទំព័រ ១៤ និង១៧។ សំណុំរឿង០០៤ ឯកសារ D117/35 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៤ ឆ.៦, ឆ.២២, ឆ.២៤, ឆ.២៧-ឆ.២៩, ឆ.៣៣-ឆ.៣៤។

[78]សំណុំរឿង០០៤ ឯកសារ D6.1.386 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ១៣។ សំណុំរឿង០០៤ ឯកសារ D117/35 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៤ ឆ.៣៦។

01336666



ជឿថា ការស្តាប់ចម្លើយសាក្សីរូបនេះឡើងវិញនឹងទទួលបានព័ត៌មានកាន់តែច្បាស់លាស់អំពីរចនាសម្ព័ន្ធធ្វើសេចក្តីសម្រេច និងខ្សែរយៈបញ្ជាការដាក់ស្តែងនៅតំបន់ ៤២ ឬក៏ការទទួលខុសត្រូវជាក់លាក់របស់ អឿន និង ស៊ូ សឿន ចំពោះកិច្ចការនយោបាយ និងសន្តិសុខ ឡើយ។

៤០. នៅឆ្នាំ ២០០៩ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានធ្វើការស្តាប់ចម្លើយយ៉ាងយូរជាមួយនឹង ស៊ូ សឿន ជាផ្នែកមួយនៃកិច្ចស៊ើបសួរសំណុំរឿង ០០២[79]។ ស៊ូ សឿន ក៏បានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២ អំពីតួនាទីរបស់គាត់ និងតួនាទីរបស់ប្តីគាត់ឈ្មោះ កែ ពក នៅក្នុងរបបរបស់ ប.ក.ក[80]។ គាត់គឺជាសាក្សីវ័យជរា និងមានការស្ទាក់ស្ទើរ ដោយសារមានការបង្ហាញឱ្យឃើញថាគាត់មានការលំបាកក្នុងការឆ្លើយសំណួរ ជាពិសេស សំណួរអំពីរចនាសម្ព័ន្ធ និងការគ្រប់គ្រងសន្តិសុខនៅស្រុកចម្ការលើ[81]។ គាត់ក៏បានអះអាងថា គាត់បានដឹងមានកម្រិតអំពីសកម្មភាព និងសិទ្ធិអំណាចរបស់ប្តីគាត់ កែ ពក នៅស្រុកចម្ការលើ នៅភូមិភាគកណ្តាល[82]។ បន្ថែមពីលើនេះទៀត នៅពេលដែលសួរអំពីការគ្រប់គ្រងសន្តិសុខនៅស្រុកចម្ការលើ ស៊ូ សឿន បានបដិសេធថា គាត់មិនបានដឹងដោយផ្ទាល់អំពីការបោសសម្អាត[83] ឬព័ត៌មាន

---

[79]សំណុំរឿង០០៤ ឯកសារD6.1.385 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ូ សឿន* ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៩។

[80]សំណុំរឿង០០៤ ឯកសារ D219/702.1.73 *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីសំណុំរឿង ០០២/០២ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥* ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥។ សំណុំរឿង០០៤ ឯកសារ D219/702.1.74 *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីសំណុំរឿង ០០២/០២ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥* ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥។

[81]សំណុំរឿង០០៤ ឯកសារ D219/702.1.73 *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីសំណុំរឿង ០០២/០២ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥* ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រ ៥, ៨, ៤០ និង ៤៩។ សំណុំរឿង០០៤ ឯកសារ D6.1.385 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ូ សឿន* ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៥។

[82]សំណុំរឿង០០៤ ឯកសារ D219/702.1.73 *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីសំណុំរឿង ០០២/០២ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥* ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រ ៥, ១៧-១៨, ៤២ និង ៤៨។ សំណុំរឿង០០៤ ឯកសារ D219/702.1.74 *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីសំណុំរឿង ០០២/០២ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥* ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រ ២៩ និង ៦១-៦២។

[83]សំណុំរឿង០០៤ ឯកសារ D6.1.385 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ូ សឿន* ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៦-៧។ សំណុំរឿង០០៤ ឯកសារ D219/702.1.73 *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីសំណុំរឿង ០០២/០២ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥* ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រ ៤១-៤២។

លម្អិតស្តីពីមន្ទីរសន្តិសុខនៅស្រុករបស់គាត់ទេ[84]។ ហេតុនេះ ខ្ញុំមិនជឿថា ការស្តាប់ចម្លើយ ស៊ូ សឿន ឡើងវិញ នឹងទទួលបានភស្តុតាងបន្ថែមដែលជួយបញ្ជាក់ពីរចនាសម្ព័ន្ធធ្វើសេចក្តីសម្រេច និងខ្សែរយៈបញ្ជាការជាក់ស្តែងនៅតំបន់ ៤២ ឬក៏ការទទួលខុសត្រូវជាក់លាក់របស់គាត់ និង អឿន ចំពោះកិច្ចការនយោបាយ និងសន្តិសុខឡើយ។

*ខ) ស្តាប់ចម្លើយ ហង្ស គឹមយេន*

៤១. ហង្ស គឹមយេន គឺជាប្រធានភូមិថ្មល់បែកលិច នៅឃុំស្វាយទាប ស្រុកចម្ការលើ។ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានជួបគាត់ នៅក្នុងអំឡុងពេលចុះបេសកកម្មនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១២[85]។ អ្នកស៊ើបអង្កេត បានកត់សម្គាល់ឃើញវ័យជរា និងស្ថានភាពសុខភាពរបស់គាត់ ហើយបានសម្រេចមិនរៀបចំការស្តាប់ចម្លើយជាមួយគាត់ឡើយទេ[86]។ នៅក្នុងកាលៈទេសៈបែបនេះ ខ្ញុំយល់ស្របតាមការវាយតម្លៃរបស់អ្នកស៊ើបអង្កេតដែលថា ការស្តាប់ចម្លើយគាត់នឹងមិនប្រើប្រាស់ធនធានរបស់ ក.ស.ច.ស ឱ្យបានប្រសិទ្ធភាពទេ។ ជាងនេះទៀត មេធាវីការពារក្តី មិនបានបង្ហាញឱ្យឃើញថាមានសំអាងហេតុជាបឋមថា ហង្ស គឹមយេន អាចមានលទ្ធភាពផ្តល់ភស្តុតាងដោះបន្ទុកទេ។

*គ) កំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយប្រតិបត្តិការទូរលេខ និងនិរសារនៅតំបន់ ៤២*

---

សំណុំរឿង០០៤ ឯកសារ D219/702.1.74 *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីសំណុំរឿង ០០២/០២ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥* ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រ ៦០។

[84]សំណុំរឿង០០៤ ឯកសារD6.1.385 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ូ សឿន* ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៩ ទំព័រ ៦-៧។ សំណុំរឿង០០៤ ឯកសារ D219/702.1.73 *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីសំណុំរឿង ០០២/០២ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥* ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រ ៣០ និង ៣៧-៣៩។

[85]សំណុំរឿង០០៤ ឯកសារ D117/13 *របាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១២* ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១២។

[86]ដូចជើងទំព័រខាងលើ។

៤២. នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានស្តាប់ចម្លើយ ឈាន ជឿន អតីតអ្នកប្រតិបត្តិការទូរលេខតំបន់ ៤២[87]។

៤៣. ដោយស្របតាមការផ្អាកកិច្ចស៊ើបសួរលើទីតាំងឧក្រិដ្ឋកម្មនៅតំបន់ ៤២ និង ៤៣ ដូចបានលើកឡើងខាងលើ[88] ខ្ញុំមិនយល់ឃើញថាចាំបាច់ត្រូវចំណាយធនធានថែមទៀតដើម្បីកំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយប្រតិបត្តិការទូរលេខ និងនិរសារនៅតំបន់ ៤២ ឡើយ ប្រសិនបើខ្ញុំមិនយល់ឃើញថាជាប់ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ អោ អាន ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅតំបន់ ៤១ ឬការចោទប្រកាន់នៅសេសសល់ទាំងអស់អំពីអំពើប្រល័យពូជសាសន៍ជនជាតិចាម នៅកំពង់ចាម។

*ឃ) ស្វែងរក និងស្តាប់ចម្លើយឈ្មោះ ហាប់ និង ជួន*

៤៤. តាមរយៈការស្តាប់ចម្លើយជាមួយនឹង ក.ស.ច.ស បាន សៀក បានចាត់តាំងឈ្មោះ "*ហាប់*" និង "*ជួន*" ឱ្យទទួលខុសត្រូវផ្នែកសន្តិសុខនៅស្រុកចម្ការលើ[89]។ ប្រសិនបើមានភស្តុតាងបញ្ជាក់អំពីករណីនេះ អ្នកទាំងពីរនេះអាចផ្តល់ភស្តុតាងដែលពាក់ព័ន្ធនឹងការចោទប្រកាន់នៅមន្ទីរសន្តិសុខចម្ការ ស្វាយចន្ទី ដែលមានទីតាំងនៅស្រុកចម្ការលើ[90]។

៤៥. ប៉ុន្តែ ខ្ញុំមិនជឿថា សំណើមានព័ត៌មានគ្រប់គ្រាន់អាចបង្កើតជាសំអាងហេតុជាបឋមថាសំណើផ្នែកនេះនឹងនាំឱ្យរកឃើញភស្តុតាងដោះបន្ទុកឡើយ។ ហេតុនេះ ការអះអាងជាទូទៅ[91] របស់មេធាវីការពារក្តី ដែលថា កិច្ចស៊ើបសួរដែលបានស្នើទាក់ទងនឹងតំបន់ ៤២ ទំនងជានាំឱ្យមានភស្តុតាងដោះបន្ទុកជាបឋមនោះ គឺជាការអះអាងដែលមិនមែនសំអាងហេតុគ្រប់គ្រាន់ទេ

[87]សំណុំរឿង00៤ ឯកសារ D219/789 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ជឿន* ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦។

[88]សំណុំរឿង00៤ ឯកសារ D307/3 *សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ* ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦។

[89]សំណុំរឿង00៤ ឯកសារ D107/15 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក* ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ៤។

[90]សំណុំរឿង00៤ ឯកសារ D107/17 *របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១២៖ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង* ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ១។

[91]សំណើ កថាខណ្ឌ ៣២។

[92]។ ដូច្នេះ កាតព្វកិច្ចដែលត្រូវស៊ើបអង្កេតលើភស្តុតាងដោះបន្ទុក អនុលោមតាមវិធានផ្ទៃក្នុង ៥៥(៥) មិនអនុវត្តឡើយនៅក្នុងករណីនេះ ហើយខ្ញុំមានឆន្ទានុសិទ្ធិទូលំទូលាយដើម្បីទទួល ឬ បដិសេធសំណើផ្នែកនេះ[93]។

៤៦. ដោយស្របតាមការផ្អាកកិច្ចស៊ើបសួរលើទីតាំងឧក្រិដ្ឋកម្មនៅតំបន់ ៤២ និង ៤៣ ដូចបាន លើកឡើងខាងលើ រាប់បញ្ចូលទាំងមន្ទីរសន្តិសុខចម្ការស្វាយចន្ទី ខ្ញុំនឹងមិនអនុញ្ញាតតាមសំណើ សុំស្វែងរក និងស្តាប់ចម្លើយឈ្មោះ ហាប់ និង ជួន ឡើយ ប្រសិនបើខ្ញុំមិនសម្រេចបើកកិច្ច ស៊ើបសួរឡើងវិញលើទីតាំងឧក្រិដ្ឋកម្មនៅតំបន់ ៤២។

*ង) កំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយសមាជិកគ្រួសារទាំងអស់របស់ កែ ពក និង តា ម៉ុក ដែលមានតំណែងផ្លូវការ ឬមិនផ្លូវការក្នុងតំបន់ ៤២*

៤៧. តាមសំអាងហេតុដែលបានបង្ហាញនៅកថាខណ្ឌ ២៨ និង ២៩ ខ្ញុំមិនមានគម្រោងអនុញ្ញាត តាមសំណើសុំធ្វើការស្រាវជ្រាវដែលអាចមានវិសាលភាពទូលំទូលាយដើម្បីស្វែងរកសាក្សី ប្រសិនបើមិនមានការបញ្ជាក់ពីអត្តសញ្ញាណ និងភាពពាក់ព័ន្ធជាមួយនឹងសាក្សីទាំងនោះ។

---

[92]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៥០។ សំណុំរឿង០០២ ឯកសារ D164/3/6 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម* ថ្ងៃទី១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៣៩។ សំណុំរឿង០០២ ឯកសារ D273/3/5 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស លើសំណើលើកទី ១៨ របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ១៩ និង ២៦។ សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៨ និង ៧៣។ សំណុំរឿង០០២ ឯកសារ D353/2/3 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ"ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១០* ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៤៧ និង ៥០។

[93]សំណុំរឿង០០២ ឯកសារ D273/3/5 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស លើសំណើលើកទី ១៨ របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ២៦។ សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៣។

## គ. តំបន់ ៤៣

*ក) កំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយសាក្សីនានា រួមមាន ចាន់ សាង និង លឹម សេង ទាក់ទងនឹងការប្រាស្រ័យទាក់ទងគ្នារវាង អ៊ុំ ស៊ីម ជាមួយនឹងកែ ពក, រវាង អ៊ុំ ស៊ីម ជាមួយនឹង តា ម៉ុក, រវាង កែ ពក ជាមួយនឹង តា ម៉ុក ឬរវាង អ៊ុំ ស៊ីម ជាមួយនឹងអ្នកក្រោមបង្គាប់គាត់*

៤៨. អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានស្តាប់ចម្លើយ ចាន់ សាង រួចហើយអំពីការប្រាស្រ័យទាក់ទងគ្នាដែលស្ថិតនៅក្នុងផ្នែកទទួលខុសត្រូវរបស់គាត់[94]។ គាត់គឺជានិរសារម្នាក់ប្រចាំនៅតំបន់ ៤៣ ដោយគាត់មានភារកិច្ចទទួលសំបុត្រពីកងចល័តទៅមន្ទីរតំបន់[95]។ គាត់បានបញ្ជាក់ថា គាត់មិនបានដឹងអំពីខ្លឹមសារនៃសារដែលគាត់បានដឹកជញ្ជូនទៅឡើយ[96] ហើយបានទទួលស្គាល់ថា គាត់ដឹងថា "*ស៊ីម* " គឺជាលេខាតំបន់ ៤៣ ប៉ុន្តែ គាត់មិនដែលបាននិយាយជាមួយគាត់ឡើយ[97]។ ចាន់ សាង បង្ហាញឲ្យឃើញថាគាត់បានដឹងអំពីការប្រាស្រ័យទាក់ទងគ្នារវាងតំបន់នានា ជាមួយនឹងកងចល័ត គឺដឹងច្រើនជាងការប្រាស្រ័យទាក់ទងគ្នារវាងសមាជិកថ្នាក់ភូមិភាគ ជាមួយនឹងសមាជិកថ្នាក់តំបន់[98]។ ដោយផ្អែកតាមការស្តាប់ចម្លើយជាមួយគាត់ គឺមិនមានមូលហេតុជឿថា គាត់អាចផ្តល់ភស្តុតាងថែមទៀតអំពីបញ្ហាដែលបានលើកឡើងនៅក្នុងសំណើរបស់មេធាវីការពារក្តី ឡើយ។

---

[94]សំណុំរឿង០០៤ ឯកសារ D219/179 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ សាង* ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៥។ សំណុំរឿង០០៤ ឯកសារ D117/21 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ សាង* ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១៣។

[95]សំណុំរឿង០០៤ ឯកសារ D219/179 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ សាង* ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.១។

[96]ដូចជើងទំព័រខាងលើ ឆ.៤។

[97]សំណុំរឿង ០០៤ ឯកសារ D117/21 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ សាង* ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.៨។ សំណុំរឿង០០៤ ឯកសារ D219/179 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ សាង* ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.២-៣។

[98]សំណុំរឿង០០៤ ឯកសារ D219/234.2.3 *មជ្ឈមណ្ឌលឯកសារកម្ពុជា សម្ភាសន៍ជាមួយ ចាន់ សាង* ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ២៤-២៦។ សំណុំរឿង០០៤ ឯកសារ D219/179 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ សាង* ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.១ និង ឆ.៣។

01336671



៤៩. អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានស្តាប់ចម្លើយ លឹម សេង ទាក់ទងនឹងការប្រាស្រ័យទាក់ទងគ្នានៅភូមិភាគកណ្តាល[99]។ លឹម សេង បានធ្វើការជាអ្នកបកប្រែទូរលេខនៅមន្ទីរផ្សព្វផ្សាយរបស់ភូមិភាគកណ្តាល ចាប់ពីឆ្នាំ ១៩៧៧[100]។ នៅចុងឆ្នាំ ១៩៧៧ គាត់ត្រូវបានចាត់តាំងឱ្យធ្វើជាអ្នកបើកឡានឱ្យ កែ ពក ហើយជូនដំណើរគាត់ ទៅតំបន់ដើម្បីចូលរួមអង្គប្រជុំ និងចុះពិនិត្យមើលការដ្ឋាន[101]។ មេធាវីការពារក្តី មិនបានបង្ហាញបញ្ហាជាក់លាក់ណាមួយដែលមិនបានលើកឡើងនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ហើយអាចផ្តល់ជាយុត្តិកម្មដែលត្រូវស្តាប់ចម្លើយសាក្សីរូបនេះម្តងទៀតទេ។

*ខ) កំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយនិរសារ អ្នកបើកបរ និងប្រតិបត្តិករទូរលេខផ្សេងទៀតដែលអាចមានព័ត៌មានអំពីការប្រាស្រ័យទាក់ទងគ្នានៅតំបន់ ៤៣*

៥០. ក.ស.ច.ស បានខិតខំប្រឹងប្រែងកំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយនិរសារ និងប្រតិបត្តិករទូរលេខផ្សេងទៀតដែលដឹងអំពីការប្រាស្រ័យទាក់ទងគ្នារវាងមជ្ឈិម ភូមិភាគកណ្តាល និងតំបន់។ កិច្ចខិតខំប្រឹងប្រែងទាំងនេះមិនបានទទួលជោគជ័យទេ ដោយសារកង្វះតម្រុយ[102]។ ដោយស្របតាមការផ្អាកកិច្ចស៊ើបសួរលើទីតាំងឧក្រិដ្ឋកម្មនៅតំបន់ ៤២ និង ៤៣ ដូចបានលើកឡើងខាងលើ[103] ខ្ញុំមិនយល់ឃើញថាចាំបាច់ត្រូវចំណាយធនធានថែមទៀតដើម្បីកំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយនិរសារ អ្នកបើកបរ និងប្រតិបត្តិករទូរលេខផ្សេងទៀតដែលអាចមានព័ត៌មានអំពីការប្រាស្រ័យទាក់ទងគ្នានៅតំបន់ ៤៣ ប្រសិនបើមិនមានការបង្ហាញថាព័ត៌មាននេះក៏អាចពាក់ព័ន្ធនឹងប្រព័ន្ធទាក់ទងគ្នានៅតំបន់ ៤១។

*គ) កំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយសាក្សីដែលអាចមានព័ត៌មានអំពីរចនាសម្ព័ន្ធធ្វើសេចក្តីសម្រេច និងខ្សែរយៈបញ្ជាការនៅតំបន់ ៤៣ ហើយអាចកំណត់អត្តសញ្ញាណសមាជិកគ្រួសារផ្សេងទៀតដែលកាន់តំណែងមានសិទ្ធិអំណាច*

---

[99]សំណុំរឿង០០៤ ឯកសារ D117/20 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សេង* ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៣។

[100]ដូចជើងទំព័រខាងលើ ធ.១។

[101]ដូចជើងទំព័រខាងលើ ធ.១ និង ធ.៧។

[102]សំណុំរឿង០០៤ ឯកសារ D219/195 *របាយការណ៍អំពីសកម្មភាពស៊ើបអង្កេត* ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥។

[103]សំណុំរឿង០០៤ ឯកសារ D307/3 *សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់ទីមួយៗ* ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦។

៥១. ក.ស.ច.ស បានខិតខំប្រឹងប្រែងកំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយសាក្សីដែលអាចមានព័ត៌មានអំពីរចនាសម្ព័ន្ធធ្វើសេចក្តីសម្រេច និងខ្សែរយៈបញ្ជាការនៅតំបន់ ៤៣ ហើយអាចកំណត់អត្តសញ្ញាណសមាជិកគ្រួសារផ្សេងទៀតដែលកាន់តំណែងមានសិទ្ធិអំណាច។ កិច្ចខិតខំប្រឹងប្រែងទាំងនេះមិនបានទទួលជោគជ័យទេ ដោយសារកង្វះតម្រុយ[104]។ ដោយស្របតាមការផ្អាកកិច្ចស៊ើបសួរលើទីតាំងឧក្រិដ្ឋកម្មនៅតំបន់ ៤២ និង ៤៣ ដូចបានលើកឡើងខាងលើ ខ្ញុំមិនយល់ឃើញថាចាំបាច់ត្រូវចំណាយធនធានថែមទៀតដើម្បីកំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយសាក្សីដែលអាចមានព័ត៌មានអំពីរចនាសម្ព័ន្ធធ្វើសេចក្តីសម្រេច និងខ្សែរយៈបញ្ជាការនៅតំបន់ ៤៣ ហើយអាចកំណត់អត្តសញ្ញាណសមាជិកគ្រួសារផ្សេងទៀតដែលកាន់តំណែងមានសិទ្ធិអំណាច។

*ឃ) កំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយសមាជិកគ្រួសារទាំងអស់របស់ កែ ពក និង តា ម៉ុក ដែលមានតំណែងផ្លូវការ ឬមិនផ្លូវការក្នុងតំបន់ ៤៣*

៥២. តាមសំអាងហេតុដែលបានបង្ហាញនៅកថាខណ្ឌ ២៨ និង ២៩ ខ្ញុំមិនមានគម្រោងអនុញ្ញាតតាមសំណើសុំធ្វើការស្រាវជ្រាវដែលអាចមានវិសាលភាពទូលំទូលាយដើម្បីស្វែងរកសាក្សី ប្រសិនបើមិនមានការបញ្ជាក់ពីអត្តសញ្ញាណ និងភាពពាក់ព័ន្ធជាមួយនឹងសាក្សីទាំងនោះទេ។

**តាមសំអាងហេតុខាងលើ ខ្ញុំ ៖**

៥៣. **ជូនដំណឹង** មេធាវីការពារក្តី ថា សំណើបានបំពេញតាមមួយចំនួនហើយ។

៥៤. **បដិសេធ**ផ្នែកផ្សេងទៀតទាំងអស់នៃសំណើ។

ភ្នំពេញ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**

[104] សំណុំរឿង004 ឯកសារ D219/195 *របាយការណ៍អំពីសកម្មភាពស៊ើបអង្កេត* ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥។